**សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍**
Khmer Kampuchea Krom for Human Rights and Development Association
ផ្ទះលេខ៦៧ ផ្លូវ៣០៩ សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ (សហគមន៍បុរីព្រៃនគរ)
#67, Street 309, (Borey Prey Nokor Community), Phnom Penh Thmey Commune, Phnom Penh
Tel: 012 993 649 / 011 994 395. E-mail: kkkyeoung@yahoo.com

លេខ៖ ........../............ល.ន.អ.

# លិខិតនិមន្ត និងអញ្ជើញ

តាងនាមអង្គការ សមាគមខ្មែរកម្ពុជាក្រោម នៅកម្ពុជា ខ្ញុំព្រះករុណា ខ្ញុំបាទមានកិត្តិយស សូមថ្វាយបង្គំប្រគេនព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងជម្រាបឯកឧត្តម លោក លោកស្រី មន្ត្រីអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងអស់ បានជ្រាបថា អង្គការ សមាគមខ្មែរកម្ពុជាក្រោមយើងទាំងអស់ នៅកម្ពុជា បានឯកភាពគ្នាបង្កើតស្ថាប័នមួយថ្មីទៀត ដែលមានឈ្មោះថា "លេខាធិការដ្ឋាន នៃអង្គការ សមាគមខ្មែរកម្ពុជក្រោម នៅកម្ពុជា" ដើម្បីជាមធ្យោបាយបម្រើឲ្យអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងអស់ធ្វើការ ដោយឈរនៅលើគោលនយោបាយខ្មែរក្រោមរួមមួយ។ តែស្ថាប័នមួយនេះ មិនទាន់បានប្រកាសសមាសភាពថ្នាក់ដឹកនាំ និងគោលនយោបាយជាសាធារណៈនៅឡើយទេ។ ដើម្បីបានប្រកាស សមាសភាព និងគោលការណ៍នៃលេខាធិការដ្ឋានបានជាសាធារណៈនោះ អង្គការ សមាគមខ្មែរកម្ពុជាក្រោមយើង នឹងបើកអង្គមហាសន្និបាតមួយ ដើម្បីប្រកាសសមាសភាពថ្នាក់ដឹកនាំ និងគោលនយោបាយ នៃលេខាធិកាដ្ឋាននោះ។

អាស្រ័យហេតុដូច្នេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអារាធនានិមន្តព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងសូមអញ្ជើញឯកឧត្តម លោក លោកស្រី សមាជិក សមាជិកា នៃបណ្តាអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងអស់ នៅកម្ពុជា ព្រមទាំងយុវជន និងនិស្សិត ចូលរួមអង្គមហាសន្និបាតលេខាធិការដ្ឋាន នៃអង្គការ សមាគមខ្មែរកម្ពុជាក្រោមយើង ឲ្យបានកុះករ ដើម្បីទទួលបានព័ត៌មានលំអិតអំពីលេខាធិការដ្ឋាននេះ។

**<u>កាលបរិច្ឆេទ</u>**

ប្រព្រឹត្តទៅនៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ០៨:០០ ព្រឹក នៅសាលប្រជុំ នៃសមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ ឋិតក្នុងសហគមន៍បុរីព្រៃនគរ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**<u>បញ្ជាក់</u>**

ចំពោះអង្គការ សមាគមខ្មែរកម្ពុជាក្រោម សូមអញ្ជើញប្រធាន ឬតំណាងក្នុងមួយស្ថាប័នចំនួន ២ រូបចូលរួម ឬច្រើនជាងនេះ កាន់តែល្អ។

**<u>ទំនាក់ទំនង</u>**

sisomna@yahoo.com
(855) 11 601 332
(855) 15 46 1949
(855) 11 217 132

ភ្នំពេញ ថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១២
ជ. អង្គការ សមាគមខ្មែរកម្ពុជាក្រោម

**សឺន យឿង**